# សំរាប់មាតាបិតា



គេហទំព័រ > សំរាប់មាតាបិតា

ផ្នែកនេះរៀបចំឡើងដោយ Sue Anderson, Cathy Sly and Rob Tebble មកពី Barrenjoey High School។ លោកនិងលោកស្រីចងក្រងបទពិសោធន៍របស់គាត់រួមគ្នា ក្នុងឋានៈជាគ្រូបង្រៀន, អ្នកផ្តល់ឱវាទ Year 12 មាតាបិតារបស់សិស្ស year 12 និងជាអ្នកផ្តល់ឱវាទផ្នែកមុខអាជីពផងដែរ។

ផ្នែកនេះបែងចែកដូចតទៅនេះ:


ការធ្វើតេស្តវាយតម្លៃ (Assessment)

ការប្រមូលព័ត៌មាន (Information gathering)

ការរៀបលក្ខណៈសំរាប់ការប្រឡង (Getting ready for the examinations)

ការរស់នៅជាមួយសិស្សរៀន HSC (Living with an HSC student)

ទម្រង់ការដាក់ពាក្យសុំចូលរៀនឧត្តមសិក្សា (Application procedures for tertiary study)

លទ្ធផល (Results)

ជីវិតក្រោយពេលការសិក្សា HSC (Life after the HSC)


## សេចក្តីផ្តើម (Introduction)

មិនមែនមានតែសិស្សទេ ដែលគិតថាការសិក្សា HSC គឺជាពេលមួយដ៏លំបាកនិងយ៉ាប់តានតឹងខ្លាំងនោះ។ នៅក្នុងអំឡុងពេលសំភាសន៍ជាមួយសិស្ស គ្រូ និងមាតាបិតា មានការបញ្ជេញឲ្យដឹងថា សមាជិកគ្រួសារក៏ត្រូវការជំនួយនៅក្នុងពេលសិស្សសិក្សា HSC ដែរ។ អ្នកទាំងនោះចង់ជួយ ប៉ុន្តែជាញឹកញយ មានការភ័យខ្លាចថាខ្លួនអាចប្រហែលជាធ្វើឲ្យមានការរំខានទៅវិញ។

នេះគឺជាឆ្នាំដែលក្រៅតែអំពីការប្រឡង HSC នោះ សិស្ស Year 12 ក៏ជាញឹកញយអាច:

- បាត់បង់ចំណាប់អារម្មណ៍ក្នុងការរៀនសូត្រ
- ពុំមានផែនការអ្វីឡើយបន្ទាប់ពីការសិក្សា HSC រួច
- បង្កើនកម្លាំងនៃសម្ព័ន្ធភាពរវាងគូសង្សារ
- យកអាជ្ញាប័ណ្ណបើកបរយានយន្ត
- ដកពិសោធន៍គ្រឿងញៀនស្របច្បាប់និងមិនស្របច្បាប់។
- មានការងារមិនពេញពេល
- ចូលជាសមាជិកនៃក្រុមកីឡាណាមួយ
- មានបញ្ហាក្នុងកាទទួលទានចំណីអាហារ
- មានការធ្លាក់ទឹកចិត្ត

ទាំងអស់នេះគឺជាបញ្ហាស្មុគស្មាញដែលអាចបណ្តាលឲ្យមាតាបិតា និងអ្នកផ្តល់ការថែទាំមានកង្វល់បន្ថែមទៀត។ ជារឿងសំខាន់ដែលលោកអ្នកជ្រាបថា លោកអ្នកមិនមែនជាមនុស្សតែម្នាក់ទេដែលមានបញ្ហាបែបនេះ។ *For Parents* ផ្តល់ព័ត៌មានស្តីអំពីភ្នាក់ងារនិងអង្គការដែលលោកអ្នកអាចទាក់ទងដើម្បីសុំជំនួយពាក់ព័ន្ធនឹងបញ្ហាផ្ទាល់ខ្លួន បញ្ហាសិក្សា និងបញ្ហាអាជីព។

ផ្នែកនេះនៃ *NSW HSC Online* មានបំណងជួយមាតាបិតា និងសមាជិកគ្រួសារឲ្យមានការយល់ដឹងអំពី:

- ការប្រឡង HSC មានការពាក់ព័ន្ធនឹងអ្វីខ្លះ
- ទីកន្លែងសំរាប់ស្វែងរកព័ត៌មានចាំបាច់
- របៀបផ្តល់ជំនួយដល់សិស្ស Year 12
- របៀបត្រៀមលក្ខណៈ មិនមែនសំរាប់តែការប្រឡងប៉ុណ្ណោះទេ តែក៏សំរាប់ពេលក្រោយ HSC ដែរ

*** សូមជ្រាបថា ព័ត៌មាននៅលើវិបសាយថ៍តភ្ជាប់ទាំងនេះ មានតែជាភាសាអង់គ្លេសទេ លើកលែងតែមានការបញ្ជាក់ឲ្យដឹង។**

## ជួយសិស្សថ្នាក់ទី ១២ របស់លោកអ្នកឲ្យសិក្សាចប់ថ្នាក់ HSC (Helping your Year 12 student through the HSC)

សេចក្តីខាងក្រោមនេះគឺផ្អែកទៅលើផ្នែកមួយនៃសេចក្តីថ្លែងសន្ទរកថាមួយរបស់លោក Richard Cracknell, ជាអ្នកប្រឹក្សាផ្តល់ឱវាទ និងជា District Guidance Officer, នៅឯកិច្ចប្រជុំពេលយប់មួយ សំរាប់មាតាបិតារបស់សិស្ស Year 12 នៅឯ Inverell ។

ប្រភេទនៃការជួយគាំទ្រជាក់ស្តែងបំផុត ដែលមាតាឬបិតាអាចស្នើខ្លួនផ្តល់ជំនួយនោះ គឺកិច្ចការពាក់ព័ន្ធនឹងកម្លាំងកាយនិងការអនុវត្ត។

- ផ្តល់នូវកន្លែងមួយដ៏ល្អសំរាប់ការសិក្សា។ កន្លែងនោះគួរមានលក្ខណៈស្ងាត់ហើយឆ្ងាយពីការរំខានទាំងពួង មានដូចជា TV, ទូរស័ព្ទ, និងការសន្ទនាជាដើម។ កន្លែងនោះគួរតែមានសីតុណ្ហភាពល្មមស្រួល ដោយមានខ្យល់ចេញចូលល្អ, មានពន្លឺល្អត្រឹមត្រូវ និងកន្លែងធំទូលាយគ្រប់គ្រាន់សំរាប់ដាក់តុមួយ។
- ផ្តល់ម្ហូបអាហារល្អត្រឹមត្រូវគ្រប់គ្រាន់។
- លើកទឹកចិត្តឲ្យមានការហាត់ប្រាណទៀងទាត់ និងការទទួលទានដំណេកក្នុងកំរិតសមរម្យ។
- លើកទឹកចិត្តឲ្យយល់ថា ការសេពសុរានិងការចូលរួមការជប់លៀងពេលរាត្រីយប់ជ្រៅហួស គួរតែមានកំរិតធុនល្មមបានហើយ។

ក្រៅតែអំពីបរិយាកាសខាងក្រៅដ៏ល្អនោះ ការយល់ចិត្តយល់ថ្លើមគឺមានសារសំខាន់។

- សំដែងនូវការជំរុញលើកទឹកចិត្តនិងជួយគាំទ្រ
- លើកអំពីចំណុចល្អនិងជោគជ័យទាំងពួង។ ជំរុញលើកទឹកចិត្តកូនលោកអ្នកឲ្យចេះគិតអំពីកំហុស ថាជាអ្វីដែលគេអាចរៀនសូត្រ ហើយខិតខំដើម្បីកែនូវកំហុសទាំងនោះ។
- សូមចងចាំថា សិស្សភាគច្រើនមានអារម្មណ៍តានតឹងគួរសមដែរ បើទុកណាលោកអ្នកមិនឃើញជាក់ស្តែងក្តី។ សិស្សជាច្រើនភ័យព្រួយថា គ្រួសារអាចបាក់មុខ ដូច្នេះសូមព្យាយាមកុំដាក់ក្តីសង្ឃឹមហួសព្រំដែនលើកូន។ សិស្សខ្លះភ័យព្រួយថា ខ្លួនមិនអាចធ្វើឲ្យបានល្អដូចជាបងប្អូនប្រុសស្រី ឬក៏សាច់ញាតិឯទៀតឡើយ។ ម៉្យាងទៀត ក៏មានការភ័យព្រួយដទៃទៀតផងដែរ មានដូចជាការត្រូវចាកចេញពីផ្ទះ ការឃ្លាតឆ្ងាយពីមិត្តភក្តិយូរណាស់មកហើយរបស់គេ ហើយនិងលទ្ធភាពដែលខ្លួនគេអាចរស់នៅកន្លែងណាមួយដែលគេមិនធ្លាប់រស់នៅ។
- ជាការធម្មតាទេចំពោះមនុស្សដែលឋិតនៅក្រោមសម្ពាធ ដែលមានអារម្មណ៍ឆាប់ប្រែប្រួលខ្លាំង រហ័សខឹងនិងមួម៉ៅម្តងម្កាលនោះ។ ដូច្នេះសូមព្យាយាមកុំប្រញាប់បញ្ចេញប្រតិកម្មហួស  នៅពេលមានហេតុការណ៍នេះកើតឡើង។
- សូមចៀសវាងការឈ្លោះប្រកែកអំពីរឿងតូចតាច មានដូចជាការភ្លេចបិទអគ្គិសនី ការភ្លេចបិទគំរបបំពង់ថ្នាំដុសធ្មេញ ហើយនិងការមិនធ្វើការងារនៅក្នុងផ្ទះជាដើម។
- សូមកុំស្លុតចិត្តនៅពេលដែលសិស្សនិយាយនៅពេលយប់មុនការប្រឡងថា ខ្លួនគេមិនដឹងមិនយល់អ្វីទាំងអស់នោះ។ និយាយលើកទឹកចិត្តសិស្សកុំឲ្យភ័យថា លោកអ្នកដឹងហើយថា គេនឹងប្រឹងអស់ពីសមត្ថភាពដែលគេអាចធ្វើបាន។

- ចៀសវាងកុំនិយាយច្រំដែល ក្នុងការប្រាប់ឲ្យសិស្សធ្វើអ្វីៗទាំងឡាយ។ គ្រាន់តែរំលឹកគេដោយទន់ភ្លន់ម្តងម្កាលទៅបានហើយ។
- សូមនិយាយលើកទឹកចិត្តកុំឲ្យសិស្សភ័យ។ បើសិនជាលោកអ្នកមានក្តីមន្ទិលអ្វីមួយ ក៏គួរតែទុកនៅក្នុងខ្លួនកុំបញ្ចេញឲ្យសោះ។
- ក្តីសង្ឃឹមរបស់លោកអ្នកគួរតែឋិតនៅក្នុងក៏រិតដែលសមរម្យអាចសំរេចទៅបាន ស្តីអំពីថាតើ HSC នេះនឹងនាំឆ្ពោះទៅរកអ្វីទៀតនោះ។ សិស្ស HSC មួយចំនួន នឹងមិនចូលរៀនបន្តនៅសកលវិទ្យាល័យឡើយ ប៉ុន្តែគេនឹងរកឃើញនូវជីវិតដ៏ល្អនិងវត្តិរើរីកវាយ ហើយនិងឱកាសសំរាប់រកការងារធ្វើ។
- ជំរុញលើកទឹកចិត្តកូនលោកអ្នកឲ្យសុំជំនួយពីគ្រូឬក៏អ្នកប្រឹក្សាផ្តល់ឱវាទនៅសាលា បើសិនជាកូនមានបញ្ហាជាមួយនឹងមុខវិជ្ជា ការរៀបចំការសិក្សា ឬក៏ការលំបាកតានតឹងចិត្ត ឬក៏ភ័យចំបែងចិត្តអំពីរឿងប្រឡង។
- រ៉ាប់ធ្វើការងារផ្ទះខ្លះជំនួសកូន នៅពេលដែលកូនមានកិច្ចការសាលាកាន់តែច្រើនដែលត្រូវធ្វើ។
- ជំរុញលើកទឹកចិត្តឲ្យកូនចេះបែងចែកពេលឲ្យបានសមរម្យរវាងការសិក្សានិងការសំរាកលំហែកាយ។ កម្មវិធីសិក្សាដ៏ល្អតែងរួមបញ្ចូលការរៀបចំពេលសំរាប់ការសំរាកផងដែរ។ ការសំរាករយៈពេលជាសរុបចំនួន ២-៣ ថ្ងៃ ជួនកាលអាចជាអ្វីដែលសិស្សត្រូវការ។
- យកចិត្តទុកដាក់ទៅនឹងអ្វីដែលកូនធ្វើ ប៉ុន្តែគួរតែធ្វើឡើងនៅក្នុងល្កិកណាដែលកូនអនុញ្ញាតឲ្យ។ សូមកុំរំខានកូនឲ្យសោះ។
- សូមកុំភ្លេចការអោបរឹតកូន ហើយនិយាយនៅគ្រាម្តងម្កាលថា លោកអ្នកស្រឡាញ់កូន។

ទោះជាបានលើកអំពីបញ្ហាទាំងនេះក៏ក៏:

សូមកុំមានអារម្មណ៍បាក់ទឹកចិត្តខ្លាំងហួស បើសិនជាលោកអ្នកបានរអ៊ូរទាំអំពីកូនលោកអ្នក ដែលមានពេលទៅចូលរួមពិធីជប់លៀងខួបកំណើត ប៉ុន្តែគ្មានពេលគ្រប់គ្រាន់សំរាប់ជួយលាងចានក្បាននោះ។ លោកអ្នកគ្រាន់តែជាមនុស្សលោកទេ ហើយជួនកាលនោះ លោកអ្នកក៏មានអារម្មណ៍ពិបាកតានតឹងដោយសារ Year 12 ដូចជាកូនលោកអ្នកអីចឹងដែរ។

ពាក្យចុងក្រោយ:

ជារឿងដែលកើតមានឡើងចៀសមិនរួចឡើយដែលថា កូនសិស្សឬក៏មាតាបិតាខ្លះនឹងមានការខកចិត្ត នៅពេលដែលលទ្ធផល HSC ចេញមក ហើយសិស្សមិនបានទទួលនូវលទ្ធផលដែលគេទន្ទឹងចង់បាន ជាពិសេសសំរាប់ការចូលទៅសិក្សានៅឧត្តមសិក្សា។ បើសិនជាហេតុការណ៍នេះកើតឡើងចំពោះគ្រួសារលោកអ្នក ឱវាទតទៅនេះប្រហែលអាចជួយលោកអ្នកបានខ្លះ:

ឧត្តមសិក្សាគឺមិនមែនជាផ្លូវតែមួយសំរាប់ឆ្ពោះទៅរកជីវិតប្រកបដោយជោគជ័យនិងសុភមង្គលនោះទេ។ សូមគិតអំពីការលូតលាស់ជាច្រើនដែលសិស្សបានទទួល ហើយអំពីរបៀបដែលសិស្សបានត្រៀមលក្ខណៈនៅគ្រាឥឡូវនេះ សំរាប់ការចេញទៅជួបប្រសព្វនៅពិភពខាងក្រៅបានល្អជាងពេល ២ ឆ្នាំកន្លងទៅនេះ។

បើសិនជាកូនមានបំណងចង់ចូលឧត្តមសិក្សានោះ មានវិធីជាច្រើនទៀតនៅពេលក្រោយ ដែលអាចនាំឆ្ពោះទៅឧត្តមសិក្សា។ អត្រាជោគជ័យនៃសិស្សដែលមានវ័យចាស់ចិត្តចាស់គំនិត គឺមានកំរិតខ្ពស់ជាងសិស្សដែលចេញពីមធ្យមសិក្សាផ្ទាល់តែម្តង។

សេចក្តីថ្លែងសុន្ទរកថានេះបានធ្វើឡើងជាលើកដំបូងនៅឆ្នាំ 1989 ។ ឥឡូវនេះ សិស្សនិងមាតាបិតារបស់គេ ប្រឈមមុខនឹងការលំបាកនៃ New HSC មួយថ្មីទៀត ប៉ុន្តែមតិខាងលើនេះនៅតែមានភាពសមរម្យសំរាប់ពេលបច្ចុប្បន្ននេះដែរ។

វិលត្រឡប់ទៅសេចក្តីផ្តើម (Return to Introduction) វិញ

វិបសាយថ៍ The NSW HSC Online © នេះឋិតនៅក្រោមការទទួលខុសត្រូវដែលមានរៀបរាប់នៅក្នុង disclaimer ▸ ។